【出典：厚生労働省　　翻訳：（公財）アジア福祉教育財団】

ដោយសារមេរោគឆ្លងកូរ៉ូណាថ្មី ត្រូវសម្រាកការងារ ឬក៏បាត់បង់ការងារ អ្នកដែលមានបញ្ហាក្នុងការចំណាយទៅលើជីវភាពលុយដើម្បី) ជីវភាព( ទាំងអស់គ្នា។

# សេចក្តីជូនដំណឹងអំពី ប្រាក់កម្ចីបន្ទាន់នៃមូលនិធិបណ្តោះអាសន្ន (អ្នកអាចខ្ចីប្រាក់ចាំបាច់មួយរយៈបាន)

ក្រុមប្រឹក្សាសុខុមាលភាពសង្គមរបស់ក្រុងខេត្ត (ទីកន្លែងដែលជួយជីវភាពរបស់អ្នក)គឺ មានជំនួយអោយខ្ចីប្រាក់ចំពោះអ្នកដែលមានបញ្ហាខ្វះប្រាក់ដើម្បីជីវភាព។ គ្រួសារដែលមានប្រាក់ចំណូល (ប្រាក់ខែ) តិច (អ្នកដែលរស់នៅក្នុងផ្ទះតែមួយ នៅជាមួយគ្នាជាក្រុម)គឺ អាចខ្ចីប្រាក់បាន។ ឥឡូវ ដោយសារតែជម្ងឺមេរោគកូរ៉ូណានឹង មានមនុស្សជាច្រើនកំពុងតែជួបបញ្ហា។ ត្រូវសម្រាកការងារ ឬក៏បាត់បង់ការងារ ប្រាក់កម្ចីពិសេស(អោយខ្ចីប្រាក់ជាពិសេស) នេះសម្រាប់អ្នកដែលមានការខ្វះប្រាក់ចំណាយក្នុងការរស់នៅមិនគ្រប់គ្រាន់ (លុយសម្រាប់រស់នៅ) ។ ព័ត៌មានលម្អិតគឺសូមមើលទៅទំព័រខាងក្រោយ។ ហើយ បើសិនជាចង់បាន ព័ត៌មានលម្អិតថែមទៀត សូមទូរសព្ទមក។

## អ្វីដែលត្រូវធ្វើនៅពេលខ្ចីប្រាក់(សូមធ្វើ①ទាំងអស់គ្នា)

① សូមដាក់ពាក្យនៅក្រុមប្រឹក្សាសុខុមាលភាពសង្គមភូមិ ឃុំ សង្កាត់ ស្រុក ក្រុង។
(បើសិនជាទៅពិគ្រោះជាមួយនឹងក្រុមប្រឹក្សាសុខុមាលភាពសង្គមភូមិ ឃុំ សង្កាត់ ស្រុក ក្រុង គេនឹងបង្រៀនអ្នកពីរបៀបដាក់ពាក្យស្នើរសុំ។)

② ក្រុមប្រឹក្សាសុខុមាលភាពសង្គមភូមិ ឃុំ សង្កាត់ ស្រុក ក្រុង នឹងបញ្ជូនពាក្យស្នើរសុំទៅក្រុមប្រឹក្សាសុខុមាលភាពសង្គមខេត្តនិងក្រុង។

③ ប្រសិនជាកម្ចីប្រាក់បានសំរេច គេនឹងផ្ញើប្រាក់ទៅឱ្យអ្នកទាំងអស់គ្នា។

ទំនាក់ទំនង (ពេលដែលអ្នកចង់ដឹងព័ត៌មានលំអិតសូមមកពិគ្រោះ)នៅ

**លំនៅដ្ឋានក្រុមប្រឹក្សាក្រុងសុខុមាលភាពសង្គមភូមិ ឃុំ សង្កាត់ ស្រុក ក្រុង**

## អ្នកដែលឈប់ពីការងារ ( ថវិកាបន្ទាន់ចំនួនតិចតួច)
## ( នឹងអោយលុយខ្ចីបានឆាប់ៗ)

អក្សរក្រហមគឺ ដោយសារមេរោគកូរ៉ូណាថ្មីបានផ្លាស់ប្តូរច្បាប់ថ្មី។

### ប្រាក់កម្ចីបន្តិចបន្តួចមួយរយៈនេះសម្រាប់អ្នកគ្មានលុយសម្រាប់ជីវភាពហើយនឹងសម្រាប់អ្នកដែលត្រូវការប្រាក់ភ្លាមៗ

■ អ្នកមានសិទ្ធិ (អ្នកដែលអាចខ្ចីលុយបាន)

ដោយសារមេរោគកូរ៉ូណាថ្មីនេះ ត្រូវសម្រាកការងារ បាត់បង់ការងារ ប្រាក់ចំណូលតិច គ្រួសារដែលត្រូវការលុយសម្រាប់ការរស់នៅ

※ មានមនុស្សជាច្រើនដែលអាចខ្ចីបាន។

※ ដោយសារតែមេរោគកូរ៉ូណាថ្មីនេះ ប្រាក់ចំណូលត្រូវបានកាត់បន្ថយ ទោះបីអ្នកកំពុងធ្វើការក៏ដោយ ក៏អ្នកអាចខ្ចីបានដែរ។

■ ចំនួនប្រាក់កម្ចីអតិបរមា (តើអាចខ្ចីបានប៉ុន្មាន)

・ អ្នកដែលបាត់បង់ការងារឬក៏សាលាសម្រាកជាដើម អ្នករកស៊ីអាជីវកម្មឯកជន(មនុស្សដែលធ្វើការឯកជន)អាចខ្ចីបាន ត្រឹមតែ ២០០,០០០ យ៉េន ក្នុងករណីពិសេស

・ អ្នកផ្សេងៗទៀតអាចខ្ចីបានត្រឹមតែ១០០,០០០ យ៉េន

※ឥឡូវក្នុងករណីពិសេសអ្នកអាចខ្ចីបាន២០០,០០០ យ៉េន។

■ការពន្យាពេល(រយៈពេលមិនចាំបាច់សងក៏បាន)

ត្រឹម១ឆ្នាំ (អ្នកមិនចាំបាច់សងវិញក្នុងរយៈពេល១ឆ្នាំបន្ទាប់ពីពេលខ្ចី)

※ពីមុនបាន「ត្រឹមតែ២ខែទេ」តែឥឡូវបានដល់「មួយឆ្នាំ」ហើយ

■ ថ្ងៃផុតកំណត់នៃការសំណង (ថ្ងៃផុតកំណត់ដែលត្រូវសងវិញ)

ត្រឹម២ឆ្នាំ (ត្រូវតែសងវិញត្រឹមកំណត់២ឆ្នាំ)

※ ពីមុនបាន「ត្រឹម១២ខែទេ」តែឥឡូវបានដល់「២ឆ្នាំ」ហើយ

■ការប្រាក់កម្ចី (ការប្រាក់លើប្រាក់កម្ចី) អ្នកធានា (អ្នកដែលធានាពេលដែលអ្នកខ្ចីប្រាក់)

ការប្រាក់គឺ ០ (សូន្យ) ។ មិនចាំបាច់មានអ្នកធានា។

■ គោលដៅពាក្យស្នើសុំ

ក្រុមប្រឹក្សាសុខុមាលភាពសង្គមភូមិ ឃុំ សង្កាត់ ស្រុក ក្រុង

## អ្នកដែលបាត់បង់ការងារជាសំខាន់ (ការជំនួយថ្លៃជីវភាព)

### រហូតដល់អ្នកអាចរស់នៅបានខ្ញុំនឹងអោយអ្នកខ្ចីប្រាក់ដែលអ្នកត្រូវការ។

■ កមានសិទ្ធិ (អ្នកដែលអាចខ្ចីលុយបាន)

ដោយសារមេរោគកូរ៉ូណាថ្មីនេះ ត្រូវសម្រាកការងារ បាត់បង់ការងារ ប្រាក់ចំណូលតិច គ្រួសារដែលពិបាកក្នុងការរស់នៅ

※ មានមនុស្សជាច្រើនដែលអាចខ្ចីបាន

※ ដោយសារតែមេរោគកូរ៉ូណាថ្មីនេះ ប្រាក់ចំណូលត្រូវបានកាត់បន្ថយ ទោះបីអ្នកកំពុងធ្វើការក៏ដោយ ក៏អ្នកអាចខ្ចីបានដែរ។

■ចំនួនប្រាក់កម្ចីអតិបរមា (តើអាចខ្ចីបានប៉ុន្មាន)

・ ក្នុងគ្រួសារមានចំនួន២នាក់ឡើងលើ ក្នុង១ខែ បានត្រឹមតែ២០០,០០០ យ៉េន

・ ក្នុងគ្រួសារមានចំនួន១នាក់ ក្នុង១ខែ បានត្រឹមតែ១៥០,០០០ យ៉េន

រយៈពេលផ្តល់ប្រាក់កម្ចី (រយៈពេលដែលអ្នកអាចខ្ចីបាន)៖ ជាទូទៅរហូតដល់ទៅ៣ខែ

■ ការពន្យាពេល(រយៈពេលមិនចាំបាច់សងក៏បាន)

ត្រឹម១ឆ្នាំ (អ្នកមិនចាំបាច់សងវិញក្នុងរយៈពេល១ឆ្នាំបន្ទាប់ពីពេលខ្ចី)

※ ពីមុនបាន「ត្រឹមតែ៦ខែទេ」តែឥឡូវបានដល់「មួយឆ្នាំ」ហើយ

■ ថ្ងៃផុតកំណត់នៃការសំណង (ថ្ងៃផុតកំណត់ដែលត្រូវសងវិញ)

ត្រឹម១០ឆ្នាំ (ត្រូវតែសងវិញត្រឹមកំណត់១០ឆ្នាំ)

■ ការប្រាក់កម្ចី (ការប្រាក់លើប្រាក់កម្ចី) អ្នកធានា (អ្នកដែលធានាពេលដែលអ្នកខ្ចីប្រាក់)

ការប្រាក់គឺ ០ (សូន្យ) ។ មិនចាំបាច់មានអ្នកធានា។

※ បើមានអ្នកធានាការប្រាក់០(សូន្យ) បើគ្មានអ្នកធានាទេ អត្រាការប្រាក់គឺ 1,5% ក្នុងមួយឆ្នាំ ប៉ុន្តែបានផ្លាស់ប្តូរហើយ។

■ គោលដៅពាក្យស្នើសុំ

ក្រុមប្រឹក្សាសុខុមាលភាពសង្គមភូមិ ឃុំ សង្កាត់ ស្រុក ក្រុង

【ចំណាំ】មិនត្រឹមតែខ្ចីប្រាក់ប៉ុណ្ណោះទេ បន្ទាប់មក,មានការជួយ ធ្វើឱ្យជីវភាពរបស់អ្នកកាន់តែងាយស្រួលបាន។

គ្រួសារលើកលែងពន្ធរស់នៅ(គ្រួសារដែលមានប្រាក់ចំណូលទាបហើយមិនចាំបាច់បង់ពន្ធនិវាសនជន) ដល់ពេលសង (ពេលដែលអ្នកត្រូវសងប្រាក់វិញ)ប្រសិនបើអ្នកនៅតែមានប្រាក់ចំណូលទាបអ្នកមិនចាំបាច់សងវិញទេ។